

# គ្រឿងយន្តដឹកជញ្ជូនកុងតឺនើរ ចាប់ផ្តើមលាចាកចេញពីការដ្ឋាន

នៅពេលដែលយើងនិយាយលាគ្នាជចុងក្រោយទៅដល់គ្រឿងយន្តស្ទូច និងគ្រឿងយន្តដឹកជញ្ជូនកុងតឺនើរ នៅ Murrumbeena យើងពិនិត្យមើលអ្វីៗគ្រប់យ៉ាងដែលគ្រឿងយន្តទាំងនេះបានជួយយើងឱ្យបានសម្រេចលទ្ធផល។

ក្នុងរយៈពេល១៨០ថ្ងៃដែលគ្រឿងយន្តដឹកជញ្ជូនកុងតឺនើរបានបើកដំណើរការ វាបានធ្វើដំណើរទៅមកជាង២៦០គីឡូម៉ែត្រតាមបណ្តោយផ្លូវដែក ខណៈដែលវាបានដំឡើងធ្នឹមបេតុងចំនួន ១៧៤ រវាង Caulfield និង Hughesdale ដែលធ្នឹមនីមួយៗមានទម្ងន់ដល់ទៅ៤២០តោន។

បច្ចុប្បន្ន គ្រឿងយន្តស្ទូចត្រូវបានដាក់ចុះមកដីវិញ ហើយគ្រឿងយន្តដឹកជញ្ជូនកុងតឺនើរកំពុងដាក់ទម្លាក់មកដីដើម្បីបញ្ឈប់ដំណើរការនៅ Murrumbeena។

ជាមួយនឹងការបញ្ចប់ដំណាក់កាលនេះ ក្រុមសំណង់នៅក្នុងផ្នែកនេះ បានផ្លាស់ប្តូរការយកចិត្តទុកដាក់របស់ពួកគេទៅកាន់ការដំឡើងផ្លូវរថភ្លើងថ្មីនៅលើរចនាសម្ព័ន ខណៈពេលយើងខិតជិតដល់ពេលយកចេញផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ដែលនៅសល់បួនទៀត រវាង Caulfield និង Dandenong។

# ព័ត៌មានអំពីពាណិជ្ជករ

ក្រុមប្តូរផ្តាច់ថៃទាំពាណិជ្ជករបានចូលរួមដោយផ្ទាល់ជាមួយអាជីវកម្មក្នុងតំបន់ក្នុងអំឡុងពេលនៃគម្រោង លើគំនិតផ្តួចផ្តើមនានាមួយចំនួនដែលផ្តល់ការគាំទ្រដល់ពាណិជ្ជករ។

ថ្មីៗនេះ ក្រុមប្តូរផ្តាច់ថៃទាំពាណិជ្ជកររបស់យើង បានចេញដំណើរទៅ Hughesdale ជាមួយក្រុមពាណិជ្ជករដ៏រស់រវើក ដែលមានទីតាំងស្ថិតនៅសងខាងនៃផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់តាមបណ្តោយផ្លូវ Poath Road។

ពួកគេទាំងអស់គ្នាបានផ្តួចផ្តើមធ្វើពិធីបុណ្យតាមដងផ្លូវផ្តោតលើគ្រួសារ ដែលសង្ឃឹមថានឹងក្លាយជាព្រឹត្តិការណ៍ប្រចាំឆ្នាំមួយនៅ Hughesdale។ ពាណិជ្ជករមួយចំនួនបានចូលរួមដោយដាក់តូបលក់តាមផ្លូវដើរ និងការលក់ជូនពិសេសសម្រាប់សហគមន៍ក្នុងតំបន់។ សមាជិកសហគមន៍បានអញ្ជើញចូលរួមដើម្បីគាំទ្រពាណិជ្ជករក្នុងតំបន់របស់ពួកគេ ដោយរីករាយជាមួយនឹងការកម្សាន្តនិងវត្ថុផ្តល់ឱ្យដោយឥតគិតថ្លៃ ហើយបានរកឃើញការលក់ទំនិញដ៏ល្អបំផុតដែលធ្វើឡើងដោយពាណិជ្ជករក្នុងតំបន់។

"ព្រឹត្តិការណ៍នេះបានលើកទឹកចិត្តយ៉ាងខ្លាំង។ ខ្ញុំមិនដែលបានឃើញមនុស្សជាច្រើននៅតាមដងផ្លូវក្នុងពេលតែមួយទេ។ យើងបានខិតទៅជិតសហគមន៍ ហើយពួកគេក៏បានខិតមកជិតយើងដែរ" ។ – **Mousa** មកពី **Knafeh Nabulseyeh**

"ក្នុងភាពជាអាជីវកម្មថ្មីមួយនៅផ្លូវ Poath Road យើងសប្បាយរីករាយដោយមានភ្ញៀវមួយចំនួនបានចូលមកហាងរបស់យើង ហើយស្វាគមន៍យើងយ៉ាងកក់ក្តៅ "។
**– Julie, Total Dance Australia**




SUPPORT
Shopping local
#SHOPLOCAL

# តារាងពេលនៃគម្រោង

## ដំណាក់កាលសាងសង់សំខាន់ៗ

### ខែតុលា ឆ្នាំ២០១៦

- ចាប់ផ្តើមការបុកបង្គោលគ្រឹះ (ការពង្រឹងដី)

### ខែមករា ឆ្នាំ២០១៧

- ដំឡើងបង្គោលសសរទ្រលើកដំបូង រវាង Carnegie និង Hughesdale
- គ្រឿងយន្តស្ទូចបានមកដល់

### ខែកុម្ភៈ - ខែឧសភា ឆ្នាំ២០១៧

- ដំឡើងបង្គោលសសរទ្រលើកដំបូងនៅ Clayton និង Noble Park
- គ្រឿងយន្តស្ទូចចាប់ផ្តើមលើកធ្នឹម និងផ្នែកនៃផ្ទៃរានស្ថានីយ ទៅលើបង្គោល សសរទ្រនៅ Clayton និង Noble Park

### ខែមិថុនា - ខែកញ្ញា ឆ្នាំ២០១៧

- ប្រព័ន្ធគ្រឿងយន្តដឹកជញ្ជូនប្រតិបត្តិការ រវាងស្ថានីយ Murrumbeena និង Grange Road
- បញ្ចប់ការបុកបង្គោលគ្រឹះនៅ Carnegie, Murrumbeena, Clayton និង Noble Park

### ចុងឆ្នាំ២០១៧

- បង្គោលសសរទ្រ និងធ្នឹមទាំងអស់បានដំឡើងនៅ Noble Park
- បញ្ចប់ការបុកបង្គោលគ្រឹះនៅ Hughesdale

### ឆ្នាំ២០១៨

- ខ្សែរថភ្លើងបានដំឡើងនៅលើផ្ទៃរានស្ថានីយដែលលើកឱ្យខ្ពស់
- បានដំឡើងអគារនៅកម្រិតផ្ទៃដី
- បញ្ចប់ការដំឡើងជញ្ជាំងទប់
- បញ្ចប់ការដាក់រាយខ្សែភ្លើងរត់ពីខាងលើរថភ្លើង
- ខ្សែរថភ្លើងចាប់ប្រតិបត្តិការ នៅលើរចនាសម្ព័នដែលបានលើកឱ្យខ្ពស់
- ស្ថានីយថ្មីៗបើកនៅ Carnegie, Murrumbeena, Hughesdale, Clayton និង Noble Park
- បញ្ចប់ផ្លូវជិះកង់ និងផ្លូវអ្នកថ្មើរជើង
- បញ្ចប់ការឈូសឆាយដី និងដាំរុក្ខជាតិនៅទីវាល

### ផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ទាំងអស់ត្រូវបានយកចេញ




## ការសាងសង់ដ៏ធំសម្បើម របស់រដ្ឋវិកថូរៀ

នាពេលបច្ចុប្បន្ននេះ រដ្ឋវិកថូរៀ កំពុងស្ថិតនៅក្នុងការរីកចម្រើនផ្នែកសាងសង់ ការដឹកជញ្ជូន ដោយមានគម្រោងកំពុងសាងសង់ផ្លូវ និងផ្លូវរថភ្លើងធំៗចំនួន២៩។

វិបសៃ Big Build របស់រដ្ឋវិកថូរៀ ផ្តល់ជូនព័ត៌មានអំពីការរំខានដល់ការធ្វើដំណើរ សម្រាប់គម្រោងធំៗទាំងនោះ។

សម្រាប់ព័ត៌មានបន្ថែម សូមបើកចូលវិបសៃ **bigbuild.vic.gov.au/about**




## ទាក់ទងមកយើង

contact@levelcrossings.vic.gov.au
1800 105 105
Level Crossing Removal Authority
GPO Box 4509, Melbourne VIC 3001

តាមយើងនៅលើប្រព័ន្ធផ្សព្វផ្សាយសង្គម
**@levelcrossings**

Interpreter

សេវាបកប្រែភាសា - សម្រាប់ភាសាផ្សេងពីភាសាអង់គ្លេស សូមទូរស័ព្ទលេខ 9280 0780។

សូមទាក់ទងមកយើង ប្រសិនបើអ្នកចង់បានព័ត៌មាននេះក្នុងទម្រង់ដែលអាចបើកមើលបាន។

CTD0706




LEVEL CROSSING REMOVAL AUTHORITY

*រថភ្លើងមួយដំបូងគេ ក្នុងចំណោមរថភ្លើងឯទៀត ដែលមកដល់ស្ថានីយ Clayton ដ៏ថ្មីថៃស*

# ព័ត៌មានទាន់បច្ចុប្បន្នភាព អំពីការយកចេញផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់

CAULFIELD ទៅ DANDENONG

ព្រឹត្តិបត្រលេខ១១ - ខែឧសភា ឆ្នាំ២០១៨

## យកចេញរួចហើយនូវផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ចំនួនប្រាំកន្លែង នៅសល់បួនទៀត

កិច្ចការសាងសង់កំពុងដំណើរការល្អ ដើម្បីយកចេញផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ សាងសង់ស្ថានីយរថភ្លើងថ្មីៗ និងបង្កើតទីវាលថ្មីនៅតាមបណ្តោយខ្សែរថភ្លើង Cranbourne – Pakenham ។

គម្រោងយកចេញផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ Caulfield ទៅ Dandenong នឹងមិនត្រឹមតែកាត់បន្ថយការរាំងស្ទះចរាចរណ៍យ៉ាងសម្បើម និងកែលម្អសុវត្ថិភាពសម្រាប់អ្នកប្រើប្រាស់ផ្លូវថ្នល់ និងរថភ្លើងប៉ុណ្ណោះទេ វាក៏នឹងអនុញ្ញាតឱ្យរថភ្លើងកាន់តែច្រើនដើម្បីបើកបរលើច្រករបៀងផ្លូវរថភ្លើងដែលមមាញឹកបំផុតរបស់ទីក្រុងម៉េលប៊ិន។

### ផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ប្រាំបួនកន្លែង កំពុងត្រូវបានយកចេញមុនដាច់ឆ្នាំ២០១៨៖

**ផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ដែលបានយកចេញរួចហើយ៖**

- Clayton Road, Clayton
- Centre Road, Clayton
- Corrigan Road, Noble Park
- Heatherton Road, Noble Park
- Chandler Road, Noble Park

**ការយកចេញផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ដែលកំពុងដំណើរការ៖**

- Grange Road, Carnegie
- Koornang Road, Carnegie
- Murrumbeena Road, Murrumbeena
- Poath Road, Hughesdale

សូមចុះឈ្មោះ ដើម្បីទទួលព័ត៌មានទាន់បច្ចុប្បន្នភាពអំពីគម្រោង
levelcrossings.vic.gov.au

អនុញ្ញាត និងបោះពុម្ពផ្សាយដោយរដ្ឋាភិបាលរដ្ឋវិចថូរៀ 1 Treasury Place, Melbourne

VICTORIA State Government









# ផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់២ថែមទៀត លែងមានរៀងរហូត

## ផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ដែលមានគ្រោះថ្នាក់ និងរាំងស្ទះនៅផ្លូវ Clayton Road និង Centre Road ក្នុងតំបន់ Clayton ត្រូវបានយកចេញជារៀងរហូត។

មុនពេលយកចេញនូវផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ទាំងនេះ វាជាប្រភពនៃការធុញថប់ និងការតានតឹងចិត្តចំពោះសហគមន៍ក្នុងតំបន់។ របាំងរាំងផ្លូវរថភ្លើងនៅកន្លែងរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ទាំងនេះ បានរាំងស្ទះចរាចរណ៍រហូតដល់ទៅ៨២នាទី ក្នុងអំឡុងពេលមមាញឹកបំផុតនៅពេលព្រឹក ដែលប៉ះពាល់ដល់ពេលវេលាធ្វើដំណើរ និងបង្កការរាំងស្ទះដល់អ្នកបើកបរយានយន្តជាង ១៨,០០០នាក់ ដែលប្រើប្រាស់ផ្លូវទាំងនេះជារៀងរាល់ថ្ងៃ។ ការយកចេញផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ទាំងនេះ ក៏នឹងផ្តល់នូវការធ្វើដំណើរកាន់តែមានសុវត្ថិភាព និងងាយស្រួលទៅកាន់ស្ថានីយ Clayton និងចំពោះពាណិជ្ជករក្នុងតំបន់។

ផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ត្រូវបានយកចេញក្នុងអំឡុងពេលសាងសង់នារដូវស្លឹកឈើជ្រុះ ដែលបានឃើញក្រុមការងាររបស់យើងបញ្ចប់ការដាក់ភ្លើងសញ្ញា ការដំឡើងខ្សែភ្លើងរត់ពីខាងលើរថភ្លើង និងការភ្ជាប់រចនាសម្ព័នដែលបានលើកឱ្យខ្ពស់ ទៅនឹងខ្សែរថភ្លើងដែលមានស្រាប់ តាមរយៈជន្ទល់ទ្រ។ ស្ថានីយរថភ្លើង Clayton ដ៏ថ្មីថែសក៏បានបើកសម្រាប់សាធារណជនផងដែរ ដោយមានក្រុមការងាររបស់យើងធ្វើការយ៉ាងមមាញឹកមិនឈប់ឈរសោះឡើយ  នៅលើកន្លែងឡើងចុះនៃស្ថានីយរថភ្លើង ទីប្រជុំ ទីលំហនៅមុខអគារ និងអគារ។

---

" វាអស្ចារ្យណាស់ដែលបានឃើញថាវាកើតមានឡើងនៅទីបំផុត។ ខ្ញុំដឹងថាក្នុងភាពជាអ្នកបើកបរ ខ្ញុំត្រូវនៅរង់ចាំមួយរយៈពេលដើម្បីបើកកាត់កន្លែងរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ទៅកាន់ហាង សាលារៀន និងទៅជួបវេជ្ជបណ្ឌិត។ វាជាការរីកចម្រើនដ៏អស្ចារ្យ មិនត្រឹមតែសម្រាប់ពេលបច្ចុប្បន្ននេះទេ ប៉ុន្តែសម្រាប់រយៈពេល១០០ឆ្នាំខាងមុខដែរ។ វាមិនត្រូវបានសាងសង់សម្រាប់ពេលបច្ចុប្បន្ននេះទេ ប៉ុន្តែសម្រាប់ពេលអនាគតផងដែរ។ **– Gayle អ្នករស់ក្នុងតំបន់**

*1. ដំឡើងបង្គោលសសរទ្រលើកដំបូងនៅ Clayton  2. បង្គោលសសរទ្រដំឡើងនៅតាមបណ្តោយផ្លូវ Carinish Road 3. ធ្នឹមដំបូងដំឡើងពីលើផ្លូវ Clayton Road  4. ធ្នឹមដំបូងដំឡើងពីលើផ្លូវ Centre Road  5. ធ្នឹមចុងក្រោយដំឡើងនៅ Clayton 6-7. បុគ្គលិកកំពុងបំពេញការងារដាក់រាយខ្សែភ្លើងរត់ពីខាងលើរថភ្លើង  8. របាំងរាំងផ្លូវរថភ្លើងនៅកន្លែងឆ្លងកាត់ផ្លូវ Clayton Road កំពុងត្រូវបានយកចេញ 9. ផ្ទៃរានស្ថានីយ Clayton បានសាងសង់រួចហើយ  10. ស្ថានីយ Clayton ក្នុងអំឡុងពេលសាងសង់*



3



4



1




8



7





# ការងារសម្រាប់កូនជាង អ្នកហាត់រៀនធ្វើការ និងនិស្សិតវិស្វកម្ម

គម្រោងយកចេញផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ កំពុងបង្កើតឱកាសរាប់រយសម្រាប់កូនជាង អ្នកហាត់រៀនធ្វើការ និងនិស្សិតវិស្វកកម្ម។

ការធានាជំនាញលើគម្រោងសំខាន់ៗ តម្រូវឱ្យអ្នកម៉ៅការងារសម្រាប់គម្រោងដែលមានតម្លៃជាង២០លានដុល្លារ ធានាថាយ៉ាងហោចណាស់១០ភាគរយនៃកម្លាំងការងាររបស់ពួកគេត្រូវបានបង្កើតឡើងដោយកូនជាង អ្នកហាត់រៀនធ្វើការ និងនិស្សិតវិស្វកម្ម។ បច្ចុប្បន្ន និស្សិតវិស្វកម្ម កូនជាង និងអ្នកហាត់រៀនធ្វើការរបស់យើងដែលធ្វើការនៅលើផ្លូវរថភ្លើង បានធ្វើការសរុបចំនួន១៧១,៥៦១ម៉ោង លើគម្រោង Caulfield ទៅ Dandenong រហូតមកដល់ពេលនេះ - គឺថាស្មើនឹងបុគ្គលិកធ្វើការពេញម៉ោងចំនួន៩៨នាក់។. និស្សិតវិស្វកម្មសិក្សាថ្នាក់បរិញ្ញាបត្រ Graduate Diploma ក្នុងផ្នែកដាក់ភ្លើងសញ្ញាតាមផ្លូវរថភ្លើងគួបផ្សំជាមួយនឹងការផ្លាស់វេនកន្លែងការងារជាច្រើននៅក្នុងរង្វង់ក្រុមហ៊ុនជាដៃគូទាំងឡាយដែលទាក់ទិនក្នុងកម្មវិធីនេះ។

"ខ្ញុំពិតជាមានមោទនភាពណាស់ ដែលបានចូលរួមជាមួយរលកនៃកិច្ចការដាក់ភ្លើងសញ្ញាតាមផ្លូវរថភ្លើងរបស់ក្រុមនិស្សិតវិស្វកម្ម។ ខ្ញុំនឹងមានឱកាសដើម្បីទុកនូវកេរ្តិ៍ដំណែល ដោយបានចូលរួមក្នុងគម្រោងយកចេញផ្លូវរថភ្លើងឆ្លងកាត់ផ្លូវថ្នល់ Caulfield ទៅ Dandenong ។" – **Christelle**
**និស្សិតវិស្វកម្មដាក់ភ្លើងសញ្ញាតាមផ្លូវរថភ្លើង**

---

# សិស្សគាំទ្រកេរ្តិ៍ដំណែលតំបន់ Clayton

នៅខែតុលា ឆ្នាំ២០១៦ យើងបានសង្គ្រោះទីជម្រកដែលបានរក្សាទុកជាកេរ្តិ៍ដំណែលនៅស្ថានីយ Clayton ដើម្បីកែលម្អឡើងវិញ និងយកទៅដាក់នៅបរិវេណស្ថានីយ Clayton ថ្មី។

កាលពីខែមុន យើងបានប្រគល់អគារទៅឱ្យវិទ្យាស្ថាន Chisholm TAFE ដើម្បីជួសជុលឡើងវិញ ជាផ្នែកនៃកម្មវិធីសិក្សារបស់សិស្ស។

គម្រោងស្មុគស្មាញនេះ ជាប់ទាក់ទងនឹងសិស្សពីមុខជំនួញផ្សេងៗរួមមានជាងឈើ និងអគ្គិសនី ដែលធ្វើការជួសជុលកែលម្អអគារឡើងវិញ នៅក្រោមការណែនាំរបស់ទីប្រឹក្សាកេរ្តិ៍ដំណែលរដ្ឋវិកថូរៀ។

ការងារមួយចំនួននឹងរួមបញ្ចូលការលាបថ្នាំទីជម្រកឡើងវិញ ការរាបដំឡើងកំរាល បង្អួច ដំបូលថ្មី និងការដំឡើងតខ្សែអគ្គិសនីឡើងវិញ។

ទីជម្រកនេះនឹងមានតាំងបង្ហាញនៅលើជញ្ជាំងខាងក្នុង អំពីផ្លូវរថភ្លើងចាស់នៅ Clayton ។

